**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
~~~~~~~

សាលាដំបូងរាជធានីភ្នំពេញ
~~~~~
សាលក្រមព្រហ្មទណ្ឌ
លេខ៧១៥ ក្រ១១ "យ១"
ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨
សំណុំរឿងព្រហ្មទណ្ឌលេខ១៤៣
ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៨
សំណុំរឿងស៊ើបសួរលេខ០៩០
ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨
សំណុំរឿងជម្រះលេខ២១២២២
ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៨ វេលាម៉ោង០៨និង៣០នាទីព្រឹក នៅសាលសវនាការទី៤ ដែលមានសមាសភាពដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក ... ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សា
លោក ... ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា
លោក ... ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក ... ជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោកស្រី ... ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះ លើសំណុំរឿងព្រហ្មទណ្ឌលេខ១៤៣ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៨ ដែលមានជនជាប់ចោទ៖

១.ឈ្មោះ **ករត** ហៅ ហ៊ីម ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកម្មកររោងចក្រ ទីកន្លែងកំណើតសង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួននៅបន្ទប់ជួលគ្មានលេខ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ... ម្តាយឈ្មោះ...(រស់) ប្រពន្ធឈ្មោះ ... ជានីតិជន ទោសពីមុនគ្មាន ។

២.ឈ្មោះ **លថរ** ហៅ ដា ភេទស្រី អាយុ២០ឆ្នាំ ជនជាតិខ្មែរ សាសនា ព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិ មេសប្រច័ន្ទ ឃុំមេសប្រច័ន្ទ ស្រុកពារាំង ខេត្តព្រៃវែង ទីលំនៅមុនពេលឃាត់ខ្លួន នៅបន្ទប់ជួលក្នុងផ្ទះសំណាក់បឹងលាភ ភូមិទួលសំពៅ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ...ម្តាយឈ្មោះ ...(រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។

មានលោក ... ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

៣.ឈ្មោះ **សវ** ហៅ រាជ អាយុ៣០ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិពោធិ៍សាលា១ ឃុំព្រែកក្របៅ ស្រុកកងមាស ខេត្តកំពង់ចាម ទីលំនៅមុនពេលឃាត់ខ្លួន នៅបន្ទប់ជួលក្នុងផ្ទះសំណាក់បឹងលាភ ភូមិទួលសំពៅ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ..(រស់) ម្តាយឈ្មោះ...(រស់) ប្រពន្ធឈ្មោះ ... កូនគ្មាន ជានីតិជន ទោសពីមុនគ្មាន ។

៤.ឈ្មោះ **របរ** ហៅ ម៉ាប់ ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមិនពិតប្រាកដ កន្លែងកំណើតនៅភូមិពោធិ៍សាលា១ ឃុំព្រែកក្របៅ ស្រុកកងមាស ខេត្តកំពង់ចាម ទីលំនៅមុនពេលឃាត់ខ្លួន នៅបន្ទប់ជួលក្នុងផ្ទះសំណាក់បឹងលាភ ភូមិទួលសំពៅ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ ...(រស់) ម្ដាយឈ្មោះ ...(រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។

មានលោកស្រី ... ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

ជាប់ចោទពីបទ៖ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

បានឃើញរបាយការណ៍សរុបលេខៈ០២៦/១៨ កបគញ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៨ របស់ការិយាល័យបទល្មើសគ្រឿងញៀននៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ ។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ១២១អ.យ.ឆ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ១៩១៦អ.យ.ឆ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ២៨១៣"ច"ដ.ដ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## ឯរឿងអង្គហេតុមានដូចតទៅ

កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ នៅចំណុចរាជធានីភ្នំពេញ បានកើតមានករណី ជួញដូរនិងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនមួយកើតឡើង ដែលអំពើនេះបង្កឡើងដោយជនជាប់ចោទ ១.ឈ្មោះ **ករន** ហៅ ហ៊ីម ភេទប្រុស អាយុ៣២ឆ្នាំ ២.ឈ្មោះ **សវ** ហៅ រាជ អាយុ៣០ឆ្នាំ ៣.ឈ្មោះ **របរ** ហៅ ម៉ាប់ ភេទប្រុស អាយុ២០ឆ្នាំ ៤.ឈ្មោះ **លថរ** ហៅ ដា ភេទស្រី អាយុ២០ឆ្នាំ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន ឆែកឆេរឃើញមានថ្នាំញៀន រួមទាំងជញ្ជីងសម្រេប់ថ្លឹងគ្រឿងញៀនចំនួន១។ នៅពេលឃាត់ខ្លួនជនជាប់ចោទខាងលើ បានឆ្លើយសារភាព ថ្នាំញៀន គឺពួកខ្លួនទិញពីឈ្មោះ **ណ** ហៅ ខ្មៅ ភេទប្រុស និងឈ្មោះ **ត** រួចសមត្ថកិច្ចក៏បានកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធី ។

ចំពោះជនជាប់ចោទ ១.ឈ្មោះ **ករន** ហៅ ហ៊ីម ភេទប្រុស អាយុ៣២ឆ្នាំ ២.ឈ្មោះ **សវ** ហៅ រាជ អាយុ៣០ឆ្នាំ ៣.ឈ្មោះ **របរ** ហៅ ម៉ាប់ ភេទប្រុស អាយុ២០ឆ្នាំ ៤.ឈ្មោះ **លថរ** ហៅ ដា ភេទស្រី អាយុ២០ឆ្នាំ ត្រូវបានសមត្ថកិច្ចពិនិត្យទឹកនោម ឃើញមានសារធាតុញៀន ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ **ករន** ហៅ ហ៊ីម បានឆ្លើយសារភាពថា៖ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ វេលាម៉ោង១៤:៣០នាទី នៅពេលខ្លួនកំពុងតែឈរលក់គ្រឿងញៀន នៅចំណុចផ្លូវរថភ្លើងម្តុំរោងចក្រឆ្នាំង

សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ស្រាប់តែមានសមត្ថកិច្ចមកធ្វើការឃាត់ខ្លួន ឆែកឆេរឃើញមានថ្នាំញៀនចំនួន១៧កញ្ចប់ចង់តូច ដែលខ្លួនបានទិញពីឈ្មោះ **ណ** ហៅ ខ្មៅ តម្លៃ ២០០$ ដើម្បីយកមកលក់បន្តយកចំណេញ ដោយលក់ខ្លួនឯងផង និងឲ្យក្មេងជួយលក់ផង។ ក្រោយពីសមត្ថកិច្ចមកធ្វើការឃាត់ខ្លួន ខ្លួនក៏នាំសមត្ថកិច្ចទៅឃាត់ខ្លួនឈ្មោះ ***សសរ*** ហៅ រាជ ដែលជាអ្នកលក់គ្រឿងញៀនដូចគ្នា និងស្រីម្នាក់ទៀតឈ្មោះ **លថរ** នៅបន្ទប់ជួលលេខ២៣ ក្នុងផ្ទះសំណាក់បឹងលាភ ហើយសមត្ថកិច្ចធ្វើការឆែកឆេរក្នុងបន្ទប់ជួលនោះ រកឃើញថ្នាំញៀនចំនួន០១កញ្ចប់ចង់ធំ និងជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនចំនួន០១ ព្រមទាំងឧបករណ៍សម្រាប់ជក់គ្រឿងញៀនមួយចំនួនទៀត ហើយជញ្ជីង និងថ្នាំញៀននេះ មិនមែនជារបស់ខ្លួនទេ។ ក្រៅពីទិញគ្រឿងញៀនពីឈ្មោះ **ណ** ហៅ ខ្មៅ យកទៅលក់បន្តខ្លួនក៏ធ្លាប់ទិញពីឈ្មោះ **ត** ម្តងម្កាលដែរ ហើយលក់រយៈពេលជិត០១ឆ្នាំហើយ និងចេះប្រើប្រាស់គ្រឿងញៀនរយៈពេល០៥ឆ្នាំ មកហើយ។ មូលហេតុដែលខ្លួននាំសមត្ថកិច្ចទៅឆែកឆេរក្នុងបន្ទប់ជួលលេខ២៣ ដែលឈ្មោះ ***សសរ*** និងឈ្មោះ **លថរ** ស្នាក់នៅ ដោយហេតុថាៈ សមត្ថកិច្ចវាយសួររកប្រភពនិងអ្នកដែលពាក់ព័ន្ធក្នុងការលក់គ្រឿងញៀននេះទើបខ្លួននាំទៅបន្ទប់របស់ឈ្មោះ ***សសរ*** តែម្តង។

-ជនជាប់ចោទឈ្មោះ ***សសរ*** ហៅ រាជ បានឆ្លើយថាៈ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ ខ្លួនបានចេញទៅក្រៅមិនបាននៅក្នុងបន្ទប់ជួលទេ នៅពេលខ្លួនត្រឡប់មកវិញស្រាប់តែឃើញមានសមត្ថកិច្ចកងរាជអាវុធហត្ថ កំពុងធ្វើការឆែកឆេរក្នុងបន្ទប់ជួលរបស់ខ្លួនលេខ២៣ ក្នុងផ្ទះសំណាក់បឹងលាភ ដែលខ្លួនចូលលុយគ្នាជាមួយឈ្មោះ **លថរ** ហៅ ដា ត្រូវជាសង្សា និងឈ្មោះ ***របរ*** ស្នាក់នៅជាមួយគ្នាចំនួន១០ថ្ងៃ។ នៅពេលឆែកឆេរសមត្ថកិច្ចបានរកឃើញថ្នាំញៀនចំនួន០១កញ្ចប់ធំ ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនចំនួន០១ ព្រមទាំងឧបករណ៍សម្រាប់ជក់គ្រឿងញៀនមួយចំនួនទៀត ដែលឈ្មោះ **លថរ** និងឈ្មោះ ***របរ*** បានប្រាប់ខ្លួនថា ឈ្មោះ **ករន** ហៅ ហ៊ីម បានយកមកផ្ញើរទុកក្នុងបន្ទប់របស់ខ្លួន រួចសមត្ថកិច្ចធ្វើការឃាត់រូបខ្លួន និងសង្សាខ្លួន(លី ថាវី) រួមជាមួយឈ្មោះ ***របរ*** នៅក្នុងបន្ទប់ជួលនោះតែម្តង។

-កន្លងមកខ្លួនធ្លាប់ទិញគ្រឿងញៀនពីឈ្មោះ **ណ** ហៅ ខ្មៅ ទិញម្តងៗទម្ងន់០៥ហ៊ុនតម្លៃ ២០០០០០៛ (ម្ភៃម៉ឺនរៀល) និងពេលខ្លះទិញពីឈ្មោះ **ត** ទិញម្តងៗទម្ងន់ ០១ជី តម្លៃ ៤០០០០០៛ (សែសិបម៉ឺនរៀល) ទិញគឺសម្រាប់តែប្រើជាមួយឈ្មោះ **លថរ** និងឈ្មោះ ***របរ*** តែប៉ុណ្ណោះ ដោយការចូលលុយគ្នាទិញយកមកជក់ មិនដែលយកទៅលក់នោះទេ។

-ជនជាប់ចោទឈ្មោះ ***របរ*** ហៅ ម៉ាប បានឆ្លើយថាៈ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ នៅពេលដែលខ្លួនកំពង់ស្នាក់នៅក្នុងបន្ទប់ជួលរបស់ខ្លួនលេខ២៣ ក្នុងផ្ទះសំណាក់បឹងលាភ ដែលឈ្មោះ ***សសរ*** ហៅ រាជ ជួលសម្រាប់ស្នាក់នៅរយៈពេល១០ថ្ងៃជាមួយសង្សាគាត់ ស្រាប់តែឃើញមានសមត្ថកិច្ចកងរាជអាវុធហត្ថ បានចុះមកធ្វើការឆែកឆេរក្នុងបន្ទប់ជួលនោះ រកឃើញថ្នាំញៀនចំនួន០១កញ្ចប់ធំ ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនចំនួន០១ ព្រមទាំងឧបករណ៍សម្រាប់ជក់គ្រឿងញៀនចំនួន០១ ហើយក៏ធ្វើការឃាត់ខ្លួនរូបខ្លួន និងឈ្មោះ ***សសរ*** ហៅ រាជ និងសង្សាគាត់ឈ្មោះ **លថរ** តែម្តង ។

ចំពោះញៀនចំនួន០១កញ្ចប់ធំ ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនចំនួន០១ ព្រមទាំងឧបករណ៍សម្រាប់ជក់គ្រឿងញៀនចំនួន០១ ខ្លួនមិនដឹងថាជារបស់អ្នកណានោះទេ តែក្នុងរយៈពេលដែលខ្លួនមកពីស្រុកមកលេងបងឈ្មោះ **សសរ** ហៅ រាជ ដោយស្នាក់នៅបន្ទប់ជួលជាមួយគ្នាពីរបីថ្ងៃនេះ ខ្លួនឃើញថា ឈ្មោះ **ករន** ហៅ ហ៊ឹម ឧស្សាហ៍ចេញចូលបន្ទប់នេះជាញឹកញាប់(បន្ទប់លេខ២៣) ហើយឃើញមានយួរថង់ខ្មៅ០១កញ្ចប់តូចមកទុកក្នុងបន្ទប់នេះ តាំងពីម៉ោង១០ព្រឹករហូតដល់៤រសៀល ក៏ត្រូវសមត្ថកិច្ចឆែកឆេរឃើញតែម្តង។

រយៈពេលដែលខ្លួនមកស្នាក់នៅបន្ទប់ជួលជាមួយបងឈ្មោះ **សសរ** ហៅ រាជ ខ្លួនពុំដែលបានប្រើប្រាស់ថ្នាំញៀនជាមួយគ្នាទេ ហើយមូលហេតុដែលខ្លួនឆ្លើយនៅចំពោះមុខនគរបាលយុត្តិធម៌កាលពីថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៨ ថា ឈ្មោះ **សសរ** ហៅ រាជ ជាអ្នកលក់គ្រឿងញៀន ហើយខ្លួនធ្លាប់លក់គ្រឿងញៀនឲ្យឈ្មោះ **សសរ** ហៅ រាជបានចំនួន០២ដង លក់ម្តងបានលុយ១០$ និងលក់ម្តងទៀតបានលុយ១៥$ ហើយឈ្មោះ **សសរ** ហៅ រាជ បានឲ្យថ្លៃឈ្នួលពីការលក់គ្រឿងញៀនចំនួន ៥០០០៛ ទៅ១០០០០៛ នោះគឺពុំពិតទេ ខ្លួនសុំបដិសេធ ដោយហេតុថា នៅពេលសួរចម្លើយខ្លួន សមត្ថកិច្ចបានទះកំភ្លៀងខ្លួនឲ្យឆ្លើយដាក់ឈ្មោះ **សសរ** ហៅ រាជ ថាបានយកថ្នាំញៀនឲ្យខ្លួនលក់ ហើយសមត្ថកិច្ចសរសេរចម្លើយដោយខ្លួនឯង ហើយបង្ខំឲ្យខ្លួនផ្តិតមេដៃ។ កន្លងមកខ្លួនពិតជាធ្លាប់បានប្រើគ្រឿងញៀនមែន តែមិនធ្លាប់បានលក់ទេ ។

-ជនជាប់ចោទឈ្មោះ **លថរ** ហៅ ដា បានឆ្លើយសារភាពថា៖ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ នៅពេលដែលខ្លួនកំពង់ស្នាក់នៅក្នុងបន្ទប់ជួលរបស់ខ្លួនលេខ២៣ក្នុងផ្ទះសំណាក់បឹងលាភ ដែលឈ្មោះ **សសរ** ហៅ រាជ ជាសង្សា ជួលសម្រាប់ស្នាក់នៅជាមួយគ្នា និងស្នាក់នៅជាមួយឈ្មោះ **របរ** ស្រាប់តែឃើញមានសមត្ថកិច្ចកងរាជអាវុធហត្ថ ក៏បានចុះមកធ្វើការឆែកឆេរក្នុងបន្ទប់ជួលនោះ រកឃើញថ្នាំញៀនចំនួន០១កញ្ចប់ធំ ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនចំនួន០១ ព្រមទាំងឧបករណ៍សម្រាប់ជក់គ្រឿងញៀនចំនួន០១ ដែលជារបស់ពួកគេទាំងបីនាក់ (**របរ**, **សសរ** និងខ្លួន **លថរ**) រួចសមត្ថកិច្ចក៏ធ្វើការឃាត់រូបខ្លួន និងឈ្មោះ សសរ ជាសង្សា ព្រមទាំងឈ្មោះ **របរ** តែម្តង ។

ខ្លួន និងឈ្មោះ **សសរ** ហៅ រាជ ទើបតែស្គាល់គ្នាបានកន្លះខែប៉ុណ្ណោះក្រោយពីទាក់ទងគ្នាធ្វើសង្សា ខ្លួនក៏ចេញពីស្រុកមករស់នៅជាមួយឈ្មោះ **សសរ** នៅក្នុងបន្ទប់ជួលលេខ២៣នេះតែម្តង ដោយឈ្មោះ **សសរ** បានឲ្យលុយខ្លួនចាយមួយថ្ងៃ ៤០០០០៛ ទៅ ៥០០០០៛ ហើយខ្លួនក៏ចេះប្រើប្រាស់គ្រឿងញៀនដោយឈ្មោះ **សសរ** ហៅ រាជ ជាអ្នកឲ្យជក់ក្នុងមួយអាទិត្យម្តងទៅពីរដង ។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានសួរដេញដោលនាពេលសវនាការនេះ ឃើញថា៖ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ នៅចំណុចរាជធានីភ្នំពេញ បានកើតមានករណីជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន មួយកើតឡើង ដែលអំពើនេះបង្កឡើងដោយជនជាប់ចោទ ១.ឈ្មោះ **ករន** ហៅ ហ៊ឹម ភេទប្រុស អាយុ៣២ឆ្នាំ ២.ឈ្មោះ **សរ** ហៅ រាជ អាយុ៣០ឆ្នាំ ៣.ឈ្មោះ **របរ** ហៅ ម៉ាប់ ភេទប្រុស អាយុ២០ឆ្នាំ ៤.ឈ្មោះ **លថរ** ហៅ ដា ភេទស្រី អាយុ២០ឆ្នាំ។ តាមចម្លើយជនជាប់ចោទឈ្មោះ ករន បានឆ្លើយសារភាពថា៖ ខ្លួនពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់របស់តំណាងអយ្យការប្រាកដមែន ឯជនជាប់ចោទឈ្មោះ **សសរ** ហៅ

រាជ និងជនជាប់ចោទឈ្មោះ **របរ** បានឆ្លើយដោះសារថា ខ្លួនមិនបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់របស់តំណាងអយ្យការទេ ការឆ្លើយសារភាពនៅដំណាក់កាលនគរបាលយុត្តិធម៌ ដោយសារមានការបង្ខិតបង្ខំពីសមត្ថកិច្ច។ ការឆ្លើយដោះសារបស់ជនជាប់ចោទ គ្រាន់តែជាចម្លើយដោះសារតែប៉ុណ្ណោះ ដោយឡែកជនជាប់ចោទឈ្មោះ **លថរ** បានឆ្លើយសារភាពទទួលស្គាល់ថ្នាំញៀនចំនួន០១កញ្ចប់ធំ ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនចំនួន០១ ព្រមទាំងឧបករណ៍សម្រាប់ជក់គ្រឿងញៀនចំនួន០១ ដែលជារបស់ពួកគេទាំងបីនាក់ (**របរ, សសវ** និងខ្លួន **លថរ**) ប្រាកដមែន។ ដូច្នេះចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ **ករន** ហៅ ហ៊ុម និងចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ **លថរ** ហៅ ដា មានភាពស៊ីសង្វាក់គ្នាទៅនឹងវត្ថុតាងដែលសមត្ថកិច្ចដកហូតបាន។ ហេតុដូច្នេះ តំណាងអយ្យការសុំតម្កល់ការចោទប្រកាន់តាមរយៈ ដីកាសន្និដ្ឋានលេខ១៩១៦ អ.យ.ឆ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកនៅដដែល ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

លោក...មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ **លថរ** ហៅ ដា និងជនជាប់ចោទឈ្មោះ **ករន** ហៅ ហ៊ុម បានធ្វើសេចក្តីសន្និដ្ឋានថាៈ កូនក្តីខ្លួនឈ្មោះ **ករន** ហៅ ហ៊ុម និងឈ្មោះ **លថរ** ហៅ ដា ពុំបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការនោះទេ កូនក្តីខ្លួនឈ្មោះ **លថរ** បានឆ្លើយបដិសេធមិនទទួលស្គាល់កញ្ចប់ថ្នាំញៀន និងជញ្ជីងមិនដឹងជារបស់អ្នកណា ហើយឈ្មោះ **សសវ** ក៏បានបដិសេធមិនទទួលស្គាល់ដោយឆ្លើយដាក់គ្នាពីមួយទៅមួយ។ ការឆ្លើយដាក់បន្ទុកលើឈ្មោះ **ករន** ហៅ ហ៊ុម គឺពុំមានសាក្សីណាម្នាក់ក្រៅពីឈ្មោះ **ករន** ហៅ ហ៊ុម ឡើយ។ ហេតុដូច្នេះ សូមក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិចារណាការចោទប្រកាន់កូនក្តីខ្លួន ដោយក្តីអនុគ្រោះ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

លោកស្រី...ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ **សសវ** ហៅ រាជ និងឈ្មោះ **របរ** ហៅ ម៉ាប់ បានធ្វើសេចក្តីសន្និដ្ឋានថាៈ កូនក្តីខ្លួនឈ្មោះ **របរ** ហៅ ម៉ាប់ និងឈ្មោះ **សសវ** ហៅ រាជ ពុំបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការនោះទេ កូនក្តីខ្លួនបានឆ្លើយបដិសេធតាំងតែពីនៅដំណាក់កាលនគរបាលយុត្តិធម៌មកម្ល៉េះថាៈ កញ្ចប់ថ្នាំញៀន និងជញ្ជីងសម្រាប់ថ្លឹងថ្នាំញៀននោះ មិនមែនជារបស់ខ្លួនទេ គឺជារបស់ឈ្មោះ **ករន** ហៅ ហ៊ុមការឆ្លើយដាក់បន្ទុកលើឈ្មោះ ករន ហៅ ហ៊ុម គឺពុំមានសាក្សីណាម្នាក់ក្រៅពីឈ្មោះ **ករន** ហៅ ហ៊ុម ឡើយ។ ហេតុដូច្នេះ សូមក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិចារណាការចោទប្រកាន់កូនក្តីខ្លួនដោយក្តីអនុគ្រោះ ។

### សម្តីចុងក្រោយរបស់ជនជាប់ចោទៈ

-ឈ្មោះ **ករន** ហៅ ហ៊ុម បានសុំឲ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសឲ្យខ្លួនផង ដើម្បីបានទៅផ្ទះវិញ ថ្ងៃក្រោយខ្លួនលែងហ៊ានប្រព្រឹត្តទៀតហើយ និងកែខ្លួនទៅជាពលរដ្ឋល្អដែលរស់នៅក្នុងសង្គម ។

-ឈ្មោះ **សសវ** ហៅ រាជ បានសុំឲ្យតុលាការមេត្តាជួយលើកលែងទោសឲ្យខ្លួនផង បានទៅជួបជុំគ្រួសារវិញផង និងបានកែខ្លួនទៅជាពលរដ្ឋល្អដែលរស់នៅក្នុងសង្គម។

-ឈ្មោះ ***របរ*** ហៅ ម៉ាប់ បានសុំឲ្យតុលាការមេត្តាសម្រេចឲ្យខ្លួនរួចផុតពីបទចោទ ព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ ។

-ឈ្មោះ ***លថរ*** ហៅ ដា បានសុំឲ្យតុលាការមេត្តាសម្រេចឲ្យខ្លួនរួចផុតពីបទចោទ ព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ ។

-ក្រោយពីបានសួរដេញដោលក្នុងអង្គសវនាការ

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសម្តីចុងក្រោយ

-ក្រោពីបានពិនិត្យភស្តុតាង និងពិចារណាលើសំណុំរឿងត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការយល់ឃើញថា

១.តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ១៤៣ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៨ មកជំនុំជម្រះតាមដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ២៨១៣"ធ"ជ.ដ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ដែលមានជនជាប់ចោទឈ្មោះ **ករន** ហៅ ហ៊ីម ភេទប្រុស អាយុ៣២ឆ្នាំ, ឈ្មោះ ***សសវ*** ហៅ រាជ ភេទប្រុស អាយុ៣០ឆ្នាំ, ឈ្មោះ ***របរ*** ហៅ ម៉ាប់ ភេទប្រុស អាយុ២០ឆ្នាំ និងឈ្មោះ ***លថរ*** ហៅ ដា ភេទស្រី អាយុ២០ឆ្នាំ ជាប់ចោទពីបទ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

និយមន័យមាត្រា៤០៖ ការកាន់កាប់ ការលាក់ទុក ប្រហាក់ប្រហែលផ្សេងទៀត ដោយខុសច្បាប់នូវសារធាតុញៀន គឺជាអំពើរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន។ ការបញ្ជូនតាមគ្រប់រូបភាព ដែលនាំឲ្យមានការផ្លាស់ទីពីកន្លែងមួយ ទៅកន្លែងមួយទៀត ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ឬពីប្រទេសមួយទៅប្រទេសមួយទៀត ដោយខុសច្បាប់នូវសារធាតុញៀនជាអាទិ៍ តាមរយៈការផ្ញើរ ការធ្វើចរាចរ ការនាំចូលឬនាំចេញ គឺជាអំពើដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន។ ការផ្តល់សម្រាប់ការលក់ ការទិញដើម្បីលក់ ឬដោះដូរដោយខុសច្បាប់នូវសារធាតុញៀន គឺជាអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។ បទរក្សាទុកដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលស្ថិតនៅតារាងទី២ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥ (ប្រាំ)ឆ្នាំ ទៅ១០ (ដប់)ឆ្នាំ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

និយមន័យមាត្រា៤៥៖ ជនណាប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុ ក្នុងតារាងទី១ និងតារាងទី២ តាមគ្រប់រូបភាព និងធ្លាប់ត្រូវបានទទួលរងនូវវិធានការព្យាបាលបង្ខំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ) ទៅ៦(ប្រាំមួយ)ខែ និងអាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១០០,០០០(មួយសែន)រៀលទៅ ១,០០០,០០០

(មួយលាន)រៀល ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងក្នុងកថាខណ្ឌទី១ និងទី២ ខាងលើ ត្រូវផ្តន្ទាទោសដូចបទមជ្ឈិមខាងលើដែរ ។

២.តាមដីកាសន្និដ្ឋានស្ថាពរលេខ៖១៩១៦អ.យ.ឆ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានបញ្ជាក់ថា៖ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ នៅចំណុចរាជធានីភ្នំពេញ ពិតជាកើតមាននូវបទល្មើស **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** បានកើតឡើងប្រាកដមែន ដែលអំពើនេះប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ ***ករន*** ហៅ ហ៊ីម ភេទប្រុស អាយុ៣២ឆ្នាំ, ឈ្មោះ ***សសរ*** ហៅ រាជ ភេទប្រុស អាយុ៣០ឆ្នាំ, ឈ្មោះ ***របរ*** ហៅ ម៉ាប់ ភេទប្រុស អាយុ២០ឆ្នាំ និងឈ្មោះ ***លថរ*** ហៅ ដា ភេទស្រី អាយុ២០ឆ្នាំ បានធ្វើសកម្មភាពជួញដូរគ្រឿងញៀនដោយខុសច្បាប់ ក៏ត្រូវបានកម្លាំសមត្ថកិច្ចការិយាល័យបទល្មើសគ្រឿងញៀននៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ ធ្វើការឃាត់ខ្លួនជនល្មើសឈ្មោះ ***ករន*** ហៅ ហ៊ីម ជាក់ស្តែងរួមជាមួយវត្ថុតាងរួចក៏បន្តឈានដល់ឃាត់ខ្លួនជនល្មើសជាបន្តបន្ទាប់ទៀត រួចកសាងសំណុំរឿងបញ្ជូនមកតុលាការតែម្តង ។

៣.តាមចម្លើយជនជាប់ចោទឈ្មោះ ***ករន*** ហៅ ហ៊ីម បានឆ្លើយសារភាពថា៖ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ វេលាម៉ោង ១៤:៣០នាទី នៅពេលខ្លួនកំពុងតែឈរលក់គ្រឿងញៀន នៅចំណុចផ្លូវរថភ្លើងមុំរោងចក្រឆ្នាំង សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ស្រាប់តែមានសមត្ថកិច្ចមកធ្វើការឃាត់ខ្លួន ឆែកឆេរឃើញមានថ្នាំញៀនចំនួន១៧កញ្ចប់ចង់តូច ដែលខ្លួនបានទិញពីឈ្មោះ ***ណ*** ហៅ ខ្មៅ តម្លៃ២០០$ ដើម្បីយកមកលក់បន្តយកចំណេញដោយលក់ខ្លួនឯងផង និងឲ្យក្មេងជួយលក់ផង ។ ក្រោយពីសមត្ថកិច្ចមកធ្វើការឃាត់ខ្លួន ខ្លួនក៏នាំសមត្ថកិច្ចទៅឃាត់ខ្លួនឈ្មោះ ***សសរ*** ហៅ រាជ ដែលជាអ្នកលក់គ្រឿងញៀនដូចគ្នា និងស្រីម្នាក់ទៀតឈ្មោះ ***លថរ*** នៅបន្ទប់ជួលលេខ២៣ក្នុងផ្ទះសំណាក់បឹងលាភ ហើយសមត្ថកិច្ចធ្វើការឆែកឆេរក្នុងបន្ទប់ជួលនោះ រកឃើញថ្នាំញៀនចំនួន០១កញ្ចប់ចង់ធំនិងជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនចំនួន០១ ព្រមទាំងឧបករណ៍សម្រាប់ជក់គ្រឿងញៀនមួយចំនួនទៀត ហើយជញ្ជីង និងថ្នាំញៀននេះមិនមែនជារបស់ខ្លួនទេ។ ក្រៅពីទិញគ្រឿងញៀនពីឈ្មោះ ***ណ*** ហៅ ខ្មៅ យកទៅលក់បន្ត ខ្លួនក៏ធ្លាប់ទិញពីឈ្មោះ ***ត*** ម្តងម្កាលដែរហើយលក់រយៈពេលជិត០១ឆ្នាំហើយ និងចេះប្រើប្រាស់គ្រឿងញៀនរយៈពេល០៥ឆ្នាំមកហើយ។ មូលហេតុដែលខ្លួននាំសមត្ថកិច្ចទៅឆែកឆេរក្នុងបន្ទប់ជួលលេខ២៣ ដែលឈ្មោះ ***សសរ*** និងឈ្មោះ ***លថរ*** ស្នាក់នៅ ដោយហេតុថាៈ សមត្ថកិច្ចវាយសួររកប្រភព និងអ្នកដែលពាក់ព័ន្ធក្នុងការលក់គ្រឿងញៀននេះ ទើបខ្លួននាំទៅបន្ទប់របស់ឈ្មោះ ***សសរ*** តែម្តង។

តាមចម្លើយជនជាប់ចោទឈ្មោះ ***ករន*** មានភាពស៊ីសង្វាក់ទៅនឹងវត្ថុតាងដែលសមត្ថកិច្ចដកហូតបានពីជនជាប់ចោទ គឺថ្នាំញៀនម្សៅក្រាមពណ៌សថ្លាចំនួន ១៧កញ្ចប់ ដែលមានទម្ងន់សរុប ២,៨២ក្រាម ។

៤.តាមចម្លើយជនជាប់ចោទឈ្មោះ ***សសរ*** ហៅ រាជ បានឆ្លើយដោះសារពេលសវនាការថា៖ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ ខ្លួនបានចេញទៅក្រៅមិនបាននៅក្នុងបន្ទប់ជួលទេ នៅពេលខ្លួនត្រឡប់មកវិញស្រាប់តែឃើញមានសមត្ថកិច្ចកងរាជអាវុធហត្ថ កំពុងធ្វើការឆែកឆេរក្នុងបន្ទប់ជួលរបស់ខ្លួនលេខ២៣ ក្នុងផ្ទះសំណាក់បឹងលាភ ដែលខ្លួនចូលលុយគ្នាជាមួយឈ្មោះ ***លថរ*** ហៅ ដា ត្រូវជាសង្សា និងឈ្មោះ ***របរ*** ស្នាក់នៅ

ជាមួយគ្នាចំនួន១០ថ្ងៃ។ នៅពេលឆែកឆេរសមត្ថកិច្ចបានរកឃើញថ្នាំញៀនចំនួន០១កញ្ចប់ធំ ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនចំនួន០១ ព្រមទាំងឧបករណ៍សម្រាប់ជក់គ្រឿងញៀនមួយចំនួនទៀត ដែលឈ្មោះ **លថរ** និងឈ្មោះ **របរ** បានប្រាប់ខ្លួនថា ឈ្មោះ **ករន** ហៅ ហ៊ីម បានយកមកផ្ញើរទុកក្នុងបន្ទប់របស់ខ្លួន រួចសមត្ថកិច្ចធ្វើការឃាត់រូបខ្លួន និងសង្សាខ្លួន(**លថរ**) រួមជាមួយឈ្មោះ **របរ** នៅក្នុងបន្ទប់ជួលនោះតែម្តង ។

កន្លងមកខ្លួនធ្លាប់ទិញគ្រឿងញៀនពីឈ្មោះ **ណ** ហៅ ខ្មៅ ទិញម្តងៗទម្ងន់០៥ហ៊ុនតម្លៃ ២០០០០០៛ (ម្ភៃម៉ឺនរៀល) និងពេលខ្លះទិញពីឈ្មោះ **ត** ទិញម្តងៗទម្ងន់ ០១ជី តម្លៃ ៤០០០០០៛ (សែសិបម៉ឺនរៀល) ទិញគឺសម្រាប់តែប្រើជាមួយឈ្មោះ **លថរ** និងឈ្មោះ **របរ** តែប៉ុណ្ណោះ ដោយការចូលលុយគ្នាទិញយកមកជក់ មិនដែលយកទៅលក់នោះទេ ។

៥.តាមចម្លើយជនជាប់ចោទឈ្មោះ **របរ** ហៅ ម៉ាប់ បានឆ្លើយថា៖ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ នៅពេលដែលខ្លួនកំពង់ស្នាក់នៅក្នុងបន្ទប់ជួលរបស់ខ្លួនលេខ២៣ ក្នុងផ្ទះសំណាក់បឹងលាភ ដែលឈ្មោះ **សសរ** ហៅ រាជ ជួលសម្រាប់ស្នាក់នៅរយៈពេល១០ថ្ងៃជាមួយសង្សាគាត់ ស្រាប់តែឃើញមានសមត្ថកិច្ចកងរាជអាវុធហត្ថ ក៏បានចុះមកធ្វើការឆែកឆេរក្នុងបន្ទប់ជួលនោះ រកឃើញថ្នាំញៀនចំនួន០១កញ្ចប់ធំជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនចំនួន០១ ព្រមទាំងឧបករណ៍សម្រាប់ជក់គ្រឿងញៀនចំនួន០១ ហើយក៏ធ្វើការឃាត់ខ្លួនរូបខ្លួន និងឈ្មោះ **សសរ** ហៅ រាជ និងសង្សាគាត់ឈ្មោះ **លថរ** តែម្តង ។

ចំពោះញៀនចំនួន០១កញ្ចប់ធំ ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនចំនួន០១ ព្រមទាំងឧបករណ៍សម្រាប់ជក់គ្រឿងញៀនចំនួន០១ ខ្លួនមិនដឹងថាជារបស់អ្នកណានោះទេ តែក្នុងរយៈពេលដែលខ្លួនមកពីស្រុកមកលេងបងឈ្មោះ **សសរ** ហៅ រាជ ដោយស្នាក់នៅបន្ទប់ជួលជាមួយគ្នាពីរបីថ្ងៃនេះ ខ្លួនឃើញថា ឈ្មោះ **ករន** ហៅ ហ៊ីម ឧស្សាហ៍ចេញចូលបន្ទប់នេះជាញឹកញាប់ (បន្ទប់លេខ២៣) ហើយឃើញមានយួរថង់ខ្មៅ០១កញ្ចប់តូចមកទុកក្នុងបន្ទប់នេះ តាំងពីម៉ោង១០ព្រឹករហូតដល់៤រសៀល ក៏ត្រូវសមត្ថកិច្ចឆែកឆេរឃើញតែម្តង។

រយៈពេលដែលខ្លួនមកស្នាក់នៅបន្ទប់ជួលជាមួយបងឈ្មោះ **សសរ** ហៅ រាជ ខ្លួនពុំដែលបានប្រើប្រាស់ថ្នាំញៀនជាមួយគ្នាទេ ហើយមូលហេតុដែលខ្លួនឆ្លើយនៅចំពោះមុខនគរបាលយុត្តិធម៌កាលពីថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៨ ថា ឈ្មោះ **សសរ** ហៅ រាជ ជាអ្នកលក់គ្រឿងញៀន ហើយខ្លួនធ្លាប់លក់គ្រឿងញៀនឲ្យឈ្មោះ **សសរ** ហៅ រាជបានចំនួន០២ដង លក់ម្តងបានលុយ១០$ និងលក់ម្តងទៀតបានលុយ១៥$ ហើយឈ្មោះ **សសរ** ហៅ រាជ បានឲ្យថ្លៃឈ្នួលពីការលក់គ្រឿងញៀនចំនួន ៥០០០៛ ទៅ១០០០០៛ នោះគឺពុំពិតទេ ខ្លួនសុំបដិសេធ ដោយហេតុថា នៅពេលសួរចម្លើយខ្លួន សមត្ថកិច្ចបានទះកំភ្លៀងខ្លួនឲ្យឆ្លើយដាក់ឈ្មោះ **សសរ** ហៅ រាជ ថាបានយកថ្នាំញៀនឲ្យខ្លួនលក់ ហើយសមត្ថកិច្ចសរសេរចម្លើយដោយខ្លួនឯង ហើយបង្ខំឲ្យខ្លួនផ្តិតមេដៃ ។ កន្លងមកខ្លួនពិតជាធ្លាប់បានប្រើគ្រឿងញៀនមែន តែមិនធ្លាប់បានលក់ទេ ។

៦.តាមចម្លើយជនជាប់ចោទឈ្មោះ **លថរ** ហៅ ដា បានឆ្លើយសារភាពថា៖ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ នៅពេលដែលខ្លួនកំពង់ស្នាក់នៅក្នុងបន្ទប់ជួលរបស់ខ្លួនលេខ២៣ក្នុងផ្ទះសំណាក់បឹងលាភ ដែលឈ្មោះ **សសរ** ហៅ រាជ ជាសង្សា ជួលសម្រាប់ស្នាក់នៅជាមួយគ្នា និងស្នាក់នៅជាមួយឈ្មោះ **របរ** ស្រាប់តែ

ឃើញមានសមត្ថកិច្ចកងរាជអាវុធហត្ថ ក៏បានចុះមកធ្វើការឆែកឆេរក្នុងបន្ទប់ជួលនោះ រកឃើញថ្នាំញៀនចំនួន០១កញ្ចប់ធំ ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនចំនួន០១ ព្រមទាំងឧបករណ៍សម្រាប់ជក់គ្រឿងញៀនចំនួន០១ ដែលជារបស់ពួកគេទាំងបីនាក់ (**របរ, សសវ** និងខ្លួន **លថរ**) រួចសមត្ថកិច្ចក៏ធ្វើការឃាត់រូបខ្លួន និងឈ្មោះ **សសវ** ជាសង្សា ព្រមទាំងឈ្មោះ **របរ** តែម្តង ។

ខ្លួន និងឈ្មោះ **សសវ** ហៅ រាជ ទើបតែស្គាល់គ្នាបានកន្លះខែប៉ុណ្ណោះក្រោយពីទាក់ទងគ្នាធ្វើសង្សា ខ្លួនក៏ចេញពីស្រុកមករស់នៅជាមួយឈ្មោះ **សសវ** នៅក្នុងបន្ទប់ជួលលេខ២៣នេះតែម្តង ដោយឈ្មោះ **សសវ** បានឲ្យលុយខ្លួនចាយមួយថ្ងៃ ៤០០០០៛ ទៅ ៥០០០០៛ ហើយខ្លួនក៏ចេះប្រើប្រាស់គ្រឿងញៀន ដោយឈ្មោះ **សសវ** ហៅ រាជ ជាអ្នកឲ្យជក់ក្នុងមួយអាទិត្យម្តងទៅពីរដង។

៧.តាមលទ្ធផលនៃការគណនាអំពីវត្ថុចាប់យក ជាសារធាតុញៀនប្រភេទមេតំហ្វេតាមីន (ហៅក្រៅ អាយ ឬម៉ាទឹកកក) ដែលជនជាប់ចោទឈ្មោះ **ករន** បានប្រព្រឹត្តមានទម្ងន់សរុប ២,៨១ក្រាម គុណភាពកម្រិតសុទ្ធ ៧៨,៩៩% ចែក១០០ ស្មើនឹង ២,២១ក្រាម ដែលស្ថិតក្នុងតាងរាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀនដូចមានចែងលម្អិត ក្នុងតារាងឧបសម្ព័ន្ធច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលតម្រូវឲ្យផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ)ឆ្នាំ ទៅ ៥ (ប្រាំ)ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ៤,០០០,០០០(បួនលាន) រៀល ទៅ ១០,០០០,០០០ (ដប់លាន)រៀល ។

៨.តាមលទ្ធផលនៃការគណនាអំពីវត្ថុចាប់យក ជាសារធាតុញៀនប្រភេទមេតំហ្វេតាមីន (ហៅក្រៅ អាយឬម៉ាទឹកកក) ដែលជនជាប់ចោទឈ្មោះឈ្មោះ **ករន** ហៅហុីម ភេទប្រុស អាយុ៣២ឆ្នាំ, ឈ្មោះ **សសវ** ហៅ រាជ ភេទប្រុស អាយុ៣០ឆ្នាំ, ឈ្មោះ **របរ** ហៅ ម៉ាប់ ភេទប្រុស អាយុ២០ឆ្នាំ និងឈ្មោះ **លថរ** ហៅ ដា បានប្រព្រឹត្តមានទម្ងន់សរុប២៥,០៣ ក្រាម គុណភាពកម្រិតសុទ្ធ ៧៦,៥៨% ចែក១០០ ស្មើនឹង ១៩,០៣ក្រាម ដែលស្ថិតក្នុងតាងរាងទី២មាត្រា៥ចំណាត់ថ្នាក់គ្រឿងញៀនដូចមានចែងលម្អិត ក្នុងតារាងឧបសម្ព័ន្ធច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលតម្រូវឲ្យផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំ ទៅ១០ (ដប់)ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ១០,០០០,០០០ (ដប់លាន)រៀល ទៅ ២០,០០០,០០០ (ម្ភៃលាន) រៀល។

៩.អំពើដែលជនជាប់ចោទឈ្មោះឈ្មោះ **ករន** ហៅ ហុីម ភេទប្រុស អាយុ៣២ឆ្នាំ, ឈ្មោះ **សសវ** ហៅ រាជ ភេទប្រុស អាយុ៣០ឆ្នាំ, ឈ្មោះ **របរ** ហៅ ម៉ាប់ ភេទប្រុស អាយុ២០ឆ្នាំ និងឈ្មោះ **លថរ** ហៅដា ដែលបានប្រព្រឹត្តអំពើទុច្ចរិត **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** នោះ តុលាការពិចារណាឃើញថាៈ ជនជាប់ចោទខាងលើ ពិតជាចារីដែលបានប្រព្រឹត្តអំពើល្មើសនេះដោយផ្ទាល់ ប្រាកដមែន ដែលអំពើនេះបានបំពានទៅនឹងនីត្យានុកូលភាពនៃព្រះរាជាណាចក្រកម្ពុជា ដែលមានចែងក្នុង បញ្ញត្តិតាមមាត្រា៤០ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១០.អំពើនិងសកម្មភាពរបស់ជនជាប់ចោទ ធ្វើឲ្យខូចសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ ប៉ះពាល់ដល់សុខភាព និងរូបរាងកាយរបស់ប្រជាពលរដ្ឋទូទៅ ដែលច្បាប់បានការពារ និងតម្រូវឲ្យផ្តន្ទាទោស

១១.ពេលធ្វើសកម្មភាព ជនជាប់ចោទមានសតិបញ្ញាស្មារតីគ្រប់គ្រាន់ យល់ដឹងពីអំពើរបស់ខ្លួន ជានីតិជន ដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត។

១២.តំណាងអយ្យការបានប្ដឹងសុំឲ្យតុលាការផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់ ដែលចំណុចនេះគប្បីតុលាការពិចារណា។

១៣.វត្ថុដែលត្រូវចាប់យករួមមាន៖

១.ស្រោមសំបុត្រពណ៌ស មានក្រាមថ្លាទម្ងន់២,៨១ក្រាម (ពីរក្បៀសប៉ែតសិបមួយក្រាម) ជារបស់ជនជាប់ចោទឈ្មោះ **ករន** ។

២.ស្រោមសំបុត្រពណ៌ស មានក្រាមថ្លាទម្ងន់២៥,០៣ក្រាម (ម្ភៃប្រាំក្បៀសសូន្យបីក្រាម) ជារបស់ជនជាប់ចោទឈ្មោះ ***សសវ***, ឈ្មោះ ***របរ*** និងឈ្មោះ លថរ ។

៣.ទូរស័ព្ទ០៣គ្រឿង ម៉ាកហូវ៉ាយ (HUAWEI) និងពីរគ្រឿងទៀត ម៉ាកណូគាខ្មៅចុចពិល ចំនួន០១គ្រឿង ពណ៌សចំនួន០១គ្រឿង ។

៤.ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនចំនួន០១ ក្រដាសអាលុយមីញ៉ូមចំនួន០១ដុំតូចដបសម្រាប់ជក់គ្រឿងញៀនចំនួន០៤ និងដែកកេះចំនួន០១ ។

១៤.មានពិរុទ្ធភាព និងភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ **ករន** ហៅ ហ៊ីម ភេទប្រុស អាយុ៣២ឆ្នាំ, ឈ្មោះ ***សសវ*** ហៅ រាជ ភេទប្រុស អាយុ៣០ឆ្នាំ, ឈ្មោះ ***របរ*** ហៅ ម៉ាប់ ភេទប្រុស អាយុ២០ឆ្នាំ និងឈ្មោះ ***លថរ*** ហៅ ដា ភេទស្រី អាយុ២០ឆ្នាំ ពីបទ៖ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

## ហេតុដូច្នេះវិនិច្ឆ័យសេចក្ដី

១.ផ្ដន្ទាទោសលើជនជាប់ចោទ៖

ក.ឈ្មោះ **ករន** ហៅ ហ៊ីម ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ

ដាក់ពន្ធនាគារកំណត់ចំនួន ៥(ប្រាំ)ឆ្នាំ ។

ខ.ឈ្មោះ ***សសវ*** ហៅ រាជ ភេទប្រុស អាយុ៣០ឆ្នាំ ជនជាតិខ្មែរ

គ.ឈ្មោះ ***របរ*** ហៅ ម៉ាប់ ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ

ឃ.ឈ្មោះ ***លថរ*** ហៅ ដា ភេទស្រី អាយុ២០ឆ្នាំ ជនជាតិខ្មែរ

ដាក់ពន្ធនាគារកំណត់ចំនួន ៦(ប្រាំមួយ)ឆ្នាំ ។

ពីបទ៖ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

២.វត្ថុចាប់យកដែលត្រូវរឹបអូសមាន៖

១.ស្រោមសំបុត្រពណ៌ស មានក្រាមថ្លាទម្ងន់២,៨១ក្រាម (ពីរក្បៀសប៉ែតសិបមួយក្រាម) ជារបស់ជនជាប់ចោទឈ្មោះ **ករន**។

២.ស្រោមសំបុត្រពណ៌ស មានក្រាមថ្លាទម្ងន់ ២៥,០៣ក្រាម (ម្ភៃប្រាំក្បៀសសូន្យបីក្រាម) ជារបស់ជនជាប់ចោទឈ្មោះ សសវ, ឈ្មោះ របរ និងឈ្មោះ លថរ។

៣.ទូរស័ព្ទ០៣គ្រឿង ម៉ាកហូវ៉ាយ (HUAWEI) និងពីរគ្រឿងទៀត ម៉ាកណូគាខ្មៅចុចពិល ចំនួន០១គ្រឿង ពណ៌សចំនួន០១គ្រឿង ។

៤.ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនចំនួន០១ ក្រដាសអាលុយមីញ៉ូមចំនួន០១ដុំតូច ដប សម្រាប់ដក់គ្រឿងញៀនចំនួន០៤ និងដែកកេះចំនួន០១ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនាថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទ ឈ្មោះ ករន ហៅ ហ៊ឹម ភេទប្រុស អាយុ៣២ឆ្នាំ, ឈ្មោះ **សសវ** ហៅ រាជ ភេទប្រុស អាយុ៣០ឆ្នាំ, ឈ្មោះ **របរ** ហៅ ម៉ាប់ ភេទប្រុស អាយុ២០ឆ្នាំ និងឈ្មោះ **លថរ** ហៅ ដា ចំពោះមុខមេធាវីកាឬពារសិទ្ធិឲ្យជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ។

ទុកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជី ចៅក្រមប្រឹក្សា ចៅក្រមប្រឹក្សា**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

... ................................